long beach unified school district

OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS
Volunteers in Public Schools

VIPS make a difference

Parent University

# របៀបត្រូវធ្វើតាមសំរាប់ដាក់ពាក្យស្នើសុំជា អ្នកស្ម័គ្រចិត្ត (VIPS) នៅតាមសាលារៀននៃក្រសួងអប់រំ ឌីស្រ្ទីគ LBUSD

**ការបំពេញក្រដាស គឺតម្រូវធ្វើ បួន ឆ្នាំម្តង**

***ការចាត់ចែងក្រដាស VIPS នឹងត្រូវចំណាយពេល ពីរ សប្តាហ៍ ឬ លើស ។ សូមលែលកពិនិត្យអំពីពត៍មានផ្សេងៗ ដែលត្រូវឆ្លើយបំពេញ និង ចុះហត្ថលេខាត្រឹមត្រូវសម្រាប់បង្ហាញនៅលើក្រដាស ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះចិត្តអត់ធ្មត់ពីអ្នក ។**

**បើមានការបង្ហាញទោសកំហុសនៅក្នុងក្រដាសដាក់ពាក្យ គឺសូមខ្ទាស់ភ្ជាប់មកផងនូវអំពីភស្តុតាងពីតុលាការ ហើយនឹងត្រូវប្រើពេលយូរបន្តិចសំរាប់ការពិនិត្យតាមដាន ។ បើមានសំនួរអ្វី សូមទាក់ទងអ្នកស្រី Dulnari Edirisinghe-Aga តាមទូរស័ព្ទលេខ (562) 997-8307 ។**

បំពេញក្រដាសដាក់ពាក្យ VIPS និង បង្ហាញភស្តុតាងនៃការជោះស្បែកពិនិត្យរោគ របេង (TB) ស្របច្បាប់តម្រូវ ។ ខ្ទាស់ភ្ជាប់ក្រដាសបង្ហាញលទ្ធផលនៃរោគរបេង និង ប័ណ្ណ សំគាល់ខ្លួន ដែលមានរូបថត ដូចជា: ប័ណ្ណបើកបរ ឬ ID ទៅជាមួយក្រដាសដាក់ពាក្យ VIPS ។ ប័ណ្ណសំគាល់ខ្លួន គឺមិនត្រូវឲ្យហួសពីថ្ងៃ/ខែ/ឆ្នាំ កំណត់ ។

↓

យកក្រដាសដាក់ពាក្យ VIPS ដែលបានបំពេញត្រឹមត្រូវ និង បានចុះហត្ថលេខាផង រួមទាំងក្រដាសបង្ហាញលទ្ធផលនៃរោគរបេង និង ប័ណ្ណសំគាល់ខ្លួន ទៅប្រគល់ជូនអ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀន ។ ភស្តុតាងអំពីរោគរបេង គឺត្រូវបង្ហាញ ថ្ងៃ/ខែ បានជោះស្បែក, ថ្ងៃ/ខែ បានពិនិត្យអំពីការជោះស្បែក (ក្នុងចន្លោះពេល 48-72 ម៉ោង), លទ្ធផលនៃការជោះស្បែក និង ឈ្មោះមន្ទីរពេទ្យ ។ មានមធ្យោបាយប្រើជំនួសម្យ៉ាង គឺអ្នកអាចបំពេញក្រដាសសំនួរអំពីរោគរបេងផ្ទាល់ខ្លួនរបស់អ្នកបាន ដែលស្ថិតនៅក្រោមការត្រួតត្រានៃបុគ្គលិកពេទ្យមានសញ្ញាប័ត្រខ្ពស់ ។ សម្រាប់ការពន្យល់អំពី x-ray សូមទាក់ទងតាមទូរស័ព្ទលេខ (562) 997-8307 ។ ការបង្ហាញប័ណ្ណសំគាល់ខ្លួន គឺត្រូវមានដូចជា: ប័ណ្ណបើកបរ, ID, ប័ណ្ណទាហាន ឬ លិខិតឆ្លងដែន ។ **រូបថតក្នុងប័ណ្ណនិមួយៗត្រូវមានភាពច្បាស់** ។

→ អ្នកស្ម័គ្រចិត្តជាគ្រូបង្ហាត់កីឡា ឬ អ្នកស្ម័គ្រចិត្តកាន់មុខងារជម្រើសផ្សេងៗ គឺត្រូវបង្ហាញភស្តុតាងជាមុខងារធ្លាប់បានត្រួតត្រាពីពេលមុនមក ឬ ទៅផ្តិតមេដៃជាមួយក្រសួង DOJ និង FBI ដែលទទួលការទាមទារឲ្យធ្វើដោយក្រសួងអប់រំឌីស្រ្ទីគ LBUSD ។

→ **Senate Bill 791 – California Daycare Immunization Requirements for Adults:** អ្នកស្ម័គ្រចិត្តទាំងអស់ ដែលនឹងធ្វើការជាមួយកុមារ ព្រីស្គូល នឹងត្រូវបង្ហាញលទ្ធផលចាក់ថ្នាំបង្ការរោគកញ្ជ្រឹល រោគក្អកមាន់ និង រោគគ្រុនផ្តាសាយធ្ងន់ ហៅ *Influenza ។ **ការចាក់ថ្នាំប្រចាំឆ្នាំសំរាប់ការពាររោគ Influenza គឺប្រហែលជាអាចទទួលការលើកលែងបាន ។**

↓

អ្នកចាត់ចែងកិច្ចការ VIPS នឹងសើរើមើលការបំពេញត្រឹមត្រូវក្នុងក្រដាសដាក់ពាក្យរបស់អ្នក និង ប្រគល់ជូននាយកសាលាសំរាប់ចុះហត្ថលេខាពីលើ ។ បន្ទាប់ទៅ, ក្រដាសដាក់ពាក្យនោះនឹងផ្ញើបន្តទៅកាន់ការិយាល័យ VIPS នៃក្រសួងអប់រំ ឌីស្រ្ទីគ LBUSD ។

↓

ការិយាល័យ VIPS នៃក្រសួងអប់រំ ឌីស្រ្ទីគ ត្រូវសើរើមើលភស្តុតាងជីវប្រវត្តិរបស់អ្នកតាមរយៈប្រើច្បាប់ Megan's Law ។

→ អ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀននឹងទទួលសំបុត្របញ្ជាក់ដោយមានផ្លាកឈ្មោះ (VIPS ID badge) របស់អ្នកសំរាប់ប្រើពាក់ផង ។ បន្ទាប់ទៅ គេនឹងទាក់ទងប្រាប់អ្នក ។

↓

ឥឡូវនេះ អ្នកអាចចាប់ផ្តើមស្ម័គ្រជួយសាលារៀនបាន ។ ដើម្បីការពារសិស្ស និង រក្សាភាពសន្តិសុខទូទៅ គឺអ្នក **ត្រូវ** កត់ឈ្មោះទុករៀងរាល់ថ្ងៃនៅពេលដើរចូល និង ចេញពីសាលារៀន ដែលអ្នកកំពុងស្ម័គ្រជួយ ហើយអ្នកត្រូវពាក់ផ្លាកឈ្មោះ ID **គ្រប់ពេលវេលា** នៅក្នុងសាលារៀន ។ អ្នក **មិនត្រូវ** យកវាចេញពីសាលារៀនទេ (លើកលែងតែនៅពេលធ្វើដំណើរទៅជាមួយសិស្ស) ឬ ចែកផ្តល់មនុស្សផ្សេងខ្ចីពាក់ប្រើ ។

**សូមអរគុណចំពោះការប្រើពេលវេលា និង ការបញ្ចេញប្រើថ្វីដៃរបស់អ្នក!**

សម្រាប់ការចាត់ចែងប្រើក្រដាស VIPS ជាផ្លូវការ គឺសូមទាក់ទងតាមទូរស័ព្ទលេខ (562) 997-8457 និង (562) 997-8307 សម្រាប់សំនួរផ្សេងៗអំពីផ្លូវច្បាប់ ។

បានកែសម្រួលឡើងវិញនៅ: 11-7-18